ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ

OPEN ACCESS

ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម
Cambodian Journal of Education and STEM

# ការលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា៖ ឱកាសនុវត្តភាព បញ្ហាប្រឈម និងអនុសាសន៍សម្រាប់គោលនយោបាយ

## Promoting research in Cambodian higher education: Opportunities, challenges, and policy implications

ហេង គ្រេង និងហេង គីមគង់*
នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា
*អ្នកនិពន្ធទទួលបន្ទុកឆ្លើយឆ្លង៖ kimkongheng@gmail.com

Kreng Heng and Kimkong Heng *
Department of Scientific Research, Ministry of Education, Youth and Sport, Phnom Penh, Cambodia
*Corresponding author: kimkongheng@gmail.com

**ទទួលបានអត្ថបទ៖** ១៦ វិច្ឆិកា ២០២២ **កែសម្រួល៖** ១៥ ធ្នូ ២០២២ **យល់ព្រមឱ្យបោះពុម្ព៖** ២៣ ធ្នូ ២០២២
**Received:** 16 November 2022 **Revised:** 15 December 2022 **Accepted:** 23 December 2022

**សេចក្ដីសង្ខេប**

- ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា មានការអភិវឌ្ឍថ្មីៗគួរឱ្យកត់សម្គាល់ក្នុងមួយទសវត្សរ៍កន្លងមកនេះ។ ទោះយ៉ាងណាក៏ដោយ កិច្ចការលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា នៅមានបញ្ហាប្រឈមជាច្រើន ដែលចាំបាច់ត្រូវដោះស្រាយជាយុទ្ធសាស្ត្រ ដើម្បីបណ្ដុះវប្បធម៌ស្រាវជ្រាវដ៏រឹងមាំមួយសម្រាប់អនុវិស័យឧត្តមសិក្សាកម្ពុជា។
- ដើម្បីធានាបាននូវដំណើរការដ៏រលូននៃការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា យើងចាំបាច់ត្រូវមានចក្ខុវិស័យ និងគោលនយោបាយច្បាស់លាស់សម្រាប់ការស្រាវជ្រាវ និងត្រូវមានការប្ដេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុច្បាស់លាស់ទាំងថ្នាក់ជាតិ និងស្ថាប័ន។ ទោះបីជាបច្ចុប្បន្ន គោលនយោបាយស្រាវជ្រាវមួយចំនួនត្រូវបានរៀបចំក៏ដោយ យើងក៏ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្រាវជ្រាវទាំងនោះ។
- ភាពចាំបាច់មួយទៀត គឺការរៀបចំប្រព័ន្ធគាំទ្រការស្រាវជ្រាវ ដែលអាចជំរុញចំណាប់អារម្មណ៍លើការស្រាវជ្រាវ និងលើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវក្នុងចំណោមអ្នកស្រាវជ្រាវ អ្នកសិក្សា និងនិស្សិតកម្ពុជា។ កិច្ចការនេះអាចសម្រេចបានតាមរយៈមធ្យោបាយផ្សេងៗ រួមមានការផ្ដល់មូលនិធិស្រាវជ្រាវដែលមានលក្ខណៈប្រកួតប្រជែង ពានរង្វាន់ស្រាវជ្រាវ លាភការសម្រាប់ស្នាដៃស្រាវជ្រាវ ការពង្រឹងសមត្ថភាពអ្នកស្រាវជ្រាវតាមរយៈការបណ្ដុះបណ្ដាល និងមគ្គុទេសក៍លើការស្រាវជ្រាវ និងការរៀបចំវេទិកាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវជាមួយអ្នកពាក់ព័ន្ធ។
- ការរៀបចំប្រព័ន្ធគាំទ្រការស្រាវជ្រាវ ពិតជាមានសារៈសំខាន់ក្នុងការបង្កើតបរិយាកាសដែលអំណោយផលដល់ការរីកចម្រើននៃការស្រាវជ្រាវ។ ការអភិវឌ្ឍបរិយាកាសល្អសម្រាប់ការស្រាវជ្រាវទាមទារការខិតខំប្រឹងប្រែង និង

ការយកចិត្តទុកដាក់ខ្ពស់ទៅលើកត្តាផ្សេងៗដែលជួយជំរុញការស្រាវជ្រាវ រួមមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ និងគម្រោងស្រាវជ្រាវ ការកសាងប្រព័ន្ធអេកូឡូស៊ីសម្រាប់គាំទ្រសកម្មភាពស្រាវជ្រាវ ដូចជាកម្មវិធីបណ្តុះបណ្តាល និងមគ្គុទេសក៍ពង្រឹងសមត្ថភាពអ្នកស្រាវជ្រាវ ការកសាងសហគមន៍អ្នកស្រាវជ្រាវ និងការជ្រើសរើស តម្លើងឋានៈ និងរក្សាទុកបុគ្គលិកសិក្សាធិការ ដែលផ្អែកលើសូចនាករសមិទ្ធផលស្រាវជ្រាវជាដើម។

**ពាក្យគន្លឹះ៖** ការស្រាវជ្រាវ កាលានុវត្តភាព បញ្ហាប្រឈម អនុសាសន៍សម្រាប់គោលនយោបាយ ឧត្តមសិក្សាកម្ពុជា

**Executive Summary**

- Research in higher education in Cambodia has seen new developments over the past decade. However, there are remaining challenges that need to be addressed to nurture a robust culture of research in the subsector.
- To ensure the smooth process of research development in Cambodian higher education, it is important to establish a clear vision and policy for research, with a clear financial commitment, at both the national and institutional levels. Although some research policies exist, more efforts are needed to ensure the effectiveness of the implementation of such research-oriented policies.
- It is also crucial to develop research-supporting mechanisms or systems that can stimulate research interests and encourage research activities among Cambodian researchers, academics, and students. This can be done through various means, including the ongoing provision of competitive research funding, research reward schemes, research incentives, research mentorship and training, and research dissemination platforms.
- The development of research-supporting mechanisms or systems is essential to nurture a conducive environment for research to grow. Developing such an environment requires a lot of efforts and commitment, and great attention needs to be paid to various factors that facilitate research, including investment in research and research infrastructure, development of an ecosystem that supports research such as research training and mentoring programs, development of communities of research practice, as well as academic promotion, recruitment, and retention that are based on research.

**Keywords:** Research; opportunities; challenges; policy implications; Cambodian higher education

## សេចក្តីផ្តើម

កម្ពុជាមានបំណងប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (Royal Government of Cambodia, 2018)។ ក្នុងបរិការណ៍ជាប្រទេសដែលមានចំនួនប្រជាជនវ័យក្មេងច្រើន កម្ពុជាមានសក្តានុពលខ្លាំងក្នុងការអភិវឌ្ឍខ្លួនឱ្យរីកចម្រើនឆាប់រហ័ស ប្រសិនប្រព័ន្ធអប់រំរបស់ខ្លួន ជាពិសេសការអប់រំឧត្តមសិក្សា បានត្រៀមខ្លួនរួចជាស្រេចក្នុងការអប់រំសិស្ស និងនិស្សិតឱ្យមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ ឆ្លើយតបទៅនឹងទីផ្សារការងារនាពេលអនាគត តម្រូវការឧស្សាហកម្ម និងការអភិវឌ្ឍរបស់ប្រទេស។ ដើម្បីសម្រេចបាននូវគោលដៅនេះ

ការវិនិយោគ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអភិវឌ្ឍការអប់រំ និងការស្រាវជ្រាវគឺចាំបាច់បំផុត។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែផលវិបាកនៃអតីតកាលរបស់ខ្លួន ប្រទេសកម្ពុជាមានឧបសគ្គច្រើនក្នុងការអភិវឌ្ឍការអប់រំ និងការស្រាវជ្រាវ (សូមអាន Heng et al., 2023; Kwok et al., 2010)។

នៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗ ដែលប្រព័ន្ធអប់រំកម្ពុជាកំពុងជួបប្រទះ (MoEYS, 2019)។ បញ្ហាប្រឈមធំៗ រួមមានសមត្ថភាពអំណាន និងគណិតវិទ្យានៅបឋមសិក្សានៅមានកម្រិត អត្រាបោះបង់ការសិក្សាខ្ពស់នៅមធ្យមសិក្សា ការចុះឈ្មោះចូលរៀននៅឧត្តមសិក្សានៅមានកម្រិតទាប គុណភាពនៃនិស្សិតបញ្ចប់ការសិក្សានៅមានកម្រិត ប្រព័ន្ធធានាគុណភាពផ្ទៃក្នុងមិនទាន់បានអនុវត្តឱ្យបានពេញលេញ ចំនួនបុគ្គលិកអប់រំដែលមានសមត្ថភាពខ្ពស់ ជាពិសេសបុគ្គលិកអប់រំមានសញ្ញាបត្របណ្ឌិតក៏នៅមានកម្រិត និងបញ្ហាកង្វះសកម្មភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា (MoEYS, 2019)។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធី ផែនការសកម្មភាព និងគម្រោងផ្សេងៗ។ នៅកម្រិតអប់រំចំណេះទូទៅ គោលនយោបាយ និងផែនការសកម្មភាពមួយចំនួន ដូចជាស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងគន្លងវិជ្ជាជីវៈគ្រូបង្រៀន ព្រមទាំងគោលនយោបាយផ្សេងទៀតត្រូវបានអនុវត្ត។ លើសពីនេះ ក្រសួងបាននិងកំពុងអនុវត្តគម្រោងសំខាន់ៗមួយចំនួន ដូចជាគម្រោងកែលម្អការអប់រំមធ្យមសិក្សា (SEIP) និងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ដើម្បីលើកកម្ពស់គុណភាពសិក្សានៅកម្រិតមធ្យមសិក្សា (Heng & Sol, 2022)។ ជាមួយគ្នានេះដែរ នៅកម្រិតឧត្តមសិក្សា គម្រោងធំៗមួយចំនួនក៏ត្រូវបាននិងកំពុងអនុវត្ត។ អ្វីដែលគួរកត់សម្គាល់ គឺគម្រោងចំនួនពីរ រួមមានគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា (HEQCIP) និងគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) ដែលមានថវិកាសរុប១១៥,៥លានដុល្លារអាម៉េរិក ត្រូវបាននិងកំពុងអនុវត្ត (Heng & Sol, 2022)។ ក្រសួងក៏កំពុងសិក្សាលើការអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សាដ៏សំខាន់មួយទៀត ដែលនឹងផ្តោតលើការផ្សារភ្ជាប់គ្នារវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម ដើម្បីលើកកម្ពស់សមត្ថភាពរបស់សាកលវិទ្យាល័យកម្ពុជា ក្នុងការធ្វើការស្រាវជ្រាវដែលផ្សារភ្ជាប់ជាមួយនឹងតម្រូវការជាតិ និងការអភិវឌ្ឍឧស្សាហកម្ម (Mak, 2022)។

ដោយមើលឃើញពីសារៈសំខាន់នៃការស្រាវជ្រាវក្នុងការជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងបរិបទនៃឧស្សាហកម្ម៤.០ និងសេដ្ឋកិច្ចផ្អែកលើចំណេះដឹង យើងចាំបាច់ត្រូវធ្វើការពិភាក្សាអំពីវឌ្ឍនភាពនៃការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជាកន្លងមក។ លើសពីនេះ យើងក៏ត្រូវពិនិត្យមើលបញ្ហាប្រឈមដែលបន្តរាំងដល់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជាផងដែរ។ ការយល់អំពីបញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់ការស្រាវជ្រាវ គឺជាជំហានដំបូងដ៏សំខាន់ ក្នុងការផ្តល់នូវអនុសាសន៍គោលនយោបាយប្រាកដនិយម ដែលអាចធ្វើឱ្យបរិយាកាសនៃការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើង ជាពិសេសផ្តល់ទិសដៅសកម្មភាពឆ្ពោះទៅរកការកសាងប្រព័ន្ធអេកូឡូស៊ីដ៏ល្អមួយសម្រាប់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។

អត្ថបទសង្ខេបគោលនយោបាយនេះ មានគោលបំណងចំនួនពីរ៖ (១) ផ្តល់នូវសេចក្តីសង្ខេបនៃកាលានុវត្តភាព និងបញ្ហាប្រឈមសំខាន់ៗទាក់ទងនឹងការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា និង (២) ផ្តល់នូវអនុសាសន៍គោលនយោបាយ ដែលអាចយកទៅពិចារណា ដើម្បីបន្តលើកកម្ពស់ការស្រាវជ្រាវ និងការបោះពុម្ពនៅក្នុងអនុវិស័យឧត្តមសិក្សាកម្ពុជា។

## កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា

ក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមកនេះ យើងសង្កេតឃើញថា កាលានុវត្តភាពជាច្រើនត្រូវបានបង្កើតឡើង សម្រាប់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ ដូចដែល Heng (2020) បានអះអាង យើងមានក្តីសង្ឃឹមថ្មីសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវនៅកម្ពុជា។ អំណះអំណាងនេះផ្អែកលើការអនុវត្តគម្រោងសំខាន់ៗចំនួនពីរ រួមមានគម្រោង HEQCIP និង HEIP ដែលផ្តល់មូលនិធិមិនធ្លាប់មានពីមុនមកសម្រាប់ការអនុវត្តគម្រោងស្រាវជ្រាវ។ លើសពីនេះ Heng (2020) ក៏បានគូសបញ្ជាក់ពីការដាក់ឱ្យប្រើប្រាស់មូលនិធិស្រាវជ្រាវជាតិ ដែលមានឈ្មោះថា 'មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍' ដែលប្រកាសដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០២០។ ដូចគ្នានេះដែរ ក្រសួងបានប្រកាសស្តីពីការជ្រើសរើសនិងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ដោយអនុញ្ញាតឱ្យសាកលវិទ្យាល័យរដ្ឋទាំងអស់ដាក់ស្នើបញ្ជីឈ្មោះគ្រូបង្រៀន និងអ្នកស្រាវជ្រាវដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយខ្លួនជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង ឬសាស្ត្រាចារ្យ។ ទោះបីជាវឌ្ឍនភាពនៃមូលនិធិស្រាវជ្រាវជាតិ និងការអនុវត្តការផ្តល់ឋានៈសាស្ត្រាចារ្យនៅមិនមានព័ត៌មានគ្រប់គ្រាន់នៅឡើយ កាលានុវត្តភាពថ្មីៗទាំងនេះ ជាភស្តុតាងនៃការអភិវឌ្ឍវិជ្ជមានមួយសម្រាប់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា (Heng, 2020)។

Heng & Sol (2021) ក៏បានពិនិត្យមើលការអភិវឌ្ឍនៃការស្រាវជ្រាវក្នុងប្រទេសកម្ពុជាផងដែរ។ ការវិវឌ្ឍនៃការស្រាវជ្រាវសំខាន់ៗចំនួនពីរ ដែលត្រូវបានគេសង្កេតឃើញ រួមមាន "ការបង្កើតវេទិកា ឬសន្និសីទស្រាវជ្រាវជាតិប្រចាំឆ្នាំ" និង "ការបង្កើតទស្សនាវដ្តីស្រាវជ្រាវមួយចំនួនដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា ដើម្បីផ្តល់វេទិកាសម្រាប់អ្នកស្រាវជ្រាវកម្ពុជាក្នុងការបោះពុម្ពផ្សាយការងារស្រាវជ្រាវរបស់ពួកគេ" (ទំព័រ១០)។ ការសង្កេតនេះ គឺមានភាពត្រឹមត្រូវ ដោយសារប៉ុន្មានឆ្នាំចុងក្រោយនេះ មានការកើនឡើងនៃចំនួនវេទិកា ឬសន្និសីទស្រាវជ្រាវ ដែលផ្តល់វេទិកាសម្រាប់អ្នកស្រាវជ្រាវ និងអ្នកចូលចិត្តការស្រាវជ្រាវកម្ពុជា ដើម្បីជួបជុំ បង្កើតទំនាក់ទំនង និងបង្ហាញលទ្ធផលស្រាវជ្រាវរបស់ពួកគេ។ ជាឧទាហរណ៍ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតវេទិកាស្រាវជ្រាវថ្នាក់ជាតិមួយ ចាប់តាំងពីឆ្នាំ២០១៩ មក។ នៅឆ្នាំ២០២២ វេទិកាស្រាវជ្រាវជាតិ លើកទី៤ លើប្រធានបទ "ការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា" ត្រូវបានប្រារព្ធឡើងនៅថ្ងៃទី២០-២១ ខែតុលា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (Department of Scientific Research [DSR], 2022a)។

សន្និសីទថ្មីៗផ្សេងទៀតក៏ត្រូវបានរៀបចំ រួមមានសន្និសីទពីរឆ្នាំម្តងនៃសហគមន៍អប់រំប្រៀបធៀបកម្ពុជា (Comparative Education Society of Cambodia) (រៀបចំឡើងដោយសហគមន៍អប់រំប្រៀបធៀបកម្ពុជា) សន្និសីទអន្តរជាតិកម្ពុជាស្តីពីអ្នកណែនាំអប់រំ (Cambodia International Conference on Mentoring Educators) (រៀបចំឡើងដោយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៃវិទ្យាស្ថានជាតិអប់រំ) សន្និសីទបង្រៀនភាសាអង់គ្លេសកម្ពុជា (Cambodian ELT Conference) (រៀបចំឡើងដោយដេប៉ាតេម៉ង់ភាសាអង់គ្លេស នៃវិទ្យាស្ថានភាសាបរទេស សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) និងវេទិកាគោលនយោបាយជាតិ (National Policy Forum) (រៀបចំឡើងដោយអង្គការមូលនិធិអាស៊ី) (សូមអាន Heng & Sol, 2021)។

Heng & Sol (2021) ក៏បានសង្កេតឃើញថា មានការបង្កើតទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រថ្មីៗក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាឧទាហរណ៍ ចាប់តាំងពីឆ្នាំ២០១៧មក ទស្សនាវដ្តីស្រាវជ្រាវមួយចំនួនត្រូវបានដាក់ឱ្យដំណើរការ ក្នុង

នោះរួមមាន (១) កាលិកបត្រអប់រំកម្ពុជា (Cambodia Education Review) (ដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៧ ដោយក្រុមប្រឹក្សាស្រាវជ្រាវអប់រំ) (២) ការយល់ដឹងៈ ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការស្រាវជ្រាវមូលដ្ឋាន និងអនុវត្ត (Insight: The Cambodia Journal of Basic and Applied Research) (ដាក់ឱ្យដំណើរការនៅឆ្នាំ២០១៩ ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ) (៣) ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាផ្នែកសុខភាពសាធារណៈ (Cambodia Journal of Public Health) (ដាក់ឱ្យដំណើរការនៅឆ្នាំ២០២០ ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ) (៤) ទស្សនាវដ្តីស្រាវជ្រាវសម្រាប់ការអភិវឌ្ឍអប់រំ (Cambodian Journal of Educational Development) (ដាក់ឱ្យដំណើរការនៅឆ្នាំ២០២១ និងគាំទ្រដោយសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា និងមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុននៅកម្ពុជា) (៥) ទស្សនាវដ្តីកម្ពុជាសម្រាប់ការស្រាវជ្រាវអប់រំ (Cambodian Journal of Educational Research) (ដាក់ឱ្យដំណើរការនៅឆ្នាំ២០២១ ដោយវេទិកាអប់រំកម្ពុជា) និង (៦) ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម (Cambodian Journal of Education and STEM) (ដាក់ឱ្យដំណើរការនៅឆ្នាំ២០២២ និងបោះពុម្ពផ្សាយលើកដំបូងនៅឆ្នាំ២០២៣ ដោយនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃក្រសួងអប់រំ យុវជន និងកីឡា) (សូមអាន DSR, 2022b)។

ជាការពិត ទស្សនាវដ្តីស្រាវជ្រាវថ្មីចំនួន១៧ ត្រូវបានដាក់ឱ្យដំណើរការក្នុងប្រទេសកម្ពុជា ចន្លោះពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ (សូមអាន DSR, 2022b)។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្សព្វផ្សាយឯកសារគោលនយោបាយស្តីពីយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ ដែលមានគោលបំណងបង្កើនសកម្មភាពស្រាវជ្រាវប្រតិបត្តិដែលផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ (MoEYS, 2021)។ ក្រសួងអប់រំ តាមរយៈនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ក៏បានផ្សព្វផ្សាយសៀវភៅណែនាំសំខាន់ៗមួយចំនួន រួមមាន (ក) សៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា (ខ) សៀវភៅណែនាំស្តីពីការបង្កើត គ្រប់គ្រង និងអភិវឌ្ឍទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ និង (គ) សៀវភៅណែនាំស្តីពីទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម។ ក្រសួងក៏មានផែនការបង្កើតមជ្ឈមណ្ឌលឧត្តមភាព (Center of Excellence) នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈគោលដៅ និងកំណត់លក្ខណៈវិនិច្ឆ័យ ដើម្បីវាយតម្លៃការបង្កើតមជ្ឈមណ្ឌលឧត្តមភាព។

លើសពីនេះទៅទៀត ក្រសួងបានបង្កើតឱ្យមានកាលានុវត្តភាពផ្សេងទៀតសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ កាលានុវត្តភាពទាំងនេះ មានដូចជាការដាក់ឱ្យដំណើរការកម្មវិធី ឬគំនិតផ្តួចផ្តើមថ្មីៗដែលគាំទ្រការស្រាវជ្រាវ ដូចជាកម្មវិធីប្រឹក្សាការស្រាវជ្រាវ កម្មវិធីមគ្គុទ្ទេសក៍អ្នកស្រាវជ្រាវវ័យក្មេង កម្មវិធីមគ្គុទ្ទេសក៍អ្នកស្រាវជ្រាវ២០២៣ សម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ ដែលផ្តល់ដោយនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ កម្មវិធីអ្នកស្រាវជ្រាវវ័យក្មេង ផ្តល់ដោយអង្គការវេទិកាអនាគត កម្មវិធីហាត់ការស្រាវជ្រាវ ផ្តល់ដោយវេទិកាអប់រំកម្ពុជា និងកម្មវិធីអាហារូបករណ៍ស្រាវជ្រាវ ផ្តល់ដោយមជ្ឈមណ្ឌលខេមរសិក្សា (Heng, 2022a)។ ដូចគ្នានេះដែរ កាលានុវត្តភាព ឬឱកាសផ្សេងទៀតសម្រាប់ការស្រាវជ្រាវរួមមានការបង្កើតបណ្តាញស្រាវជ្រាវថ្មី (ឧ. បណ្តាញអ្នកស្រាវជ្រាវស្ត្រី) ការតម្រូវឱ្យនិស្សិតធ្វើការស្រាវជ្រាវ (ឧ. វិទ្យាស្ថានបណ្តុះបណ្តាលគរុកោសល្យភ្នំពេញ និងវិទ្យាស្ថានបណ្តុះបណ្តាលគរុកោសល្យបាត់ដំបង) និងការបន្តគាំទ្រដល់ការអភិវឌ្ឍការស្រាវជ្រាវពីដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារផ្តល់ជំនួយ (ឧ. អង្គការស៊ីដា ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី ធនាគារពិភពលោក។ល។) (Heng, 2022a)។

## បញ្ហាប្រឈមក្នុងការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា

ទោះបីជាមានកាលានុវត្តភាពមួយចំនួនដូចបានពិភាក្សាខាងលើក៏ដោយ ក៏មានបញ្ហាប្រឈមជាច្រើនដែលបន្តរាំងដល់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ បញ្ហាប្រឈមសំខាន់មួយគឺកង្វះប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវច្បាស់លាស់ ទាំងថ្នាក់ជាតិ និងស្ថាប័ន។ ដោយយល់ពីបញ្ហានេះ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមគាំទ្រសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវរបស់ពួកគេ ដោយដាក់ចេញនូវសៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា (សូមមើល DSR, 2022c)។ ទោះជាយ៉ាងណាក៏ដោយ វានៅតែជាផ្លូវដ៏វែងឆ្ងាយមួយ មុនពេលដែលប្រព័ន្ធគាំទ្រការស្រាវជ្រាវមួយអាចមានដំណើរការបានល្អប្រសើរនៅកម្ពុជា។

Kwok et al. (2010) បានរកឃើញបញ្ហាប្រឈមមួយចំនួនចំពោះការអភិវឌ្ឍការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា។ បញ្ហាប្រឈមទាំងនោះ រួមមាន "ប្រាក់ខែទាបសម្រាប់ គ្រូបង្រៀនសាកលវិទ្យាល័យ ដែលបង្ខំឱ្យពួកគេធ្វើការនៅច្រើនស្ថាប័ន និងបណ្តាលឱ្យមានការចាកចេញពីសាកលវិទ្យាល័យ កង្វះគន្លងវិជ្ជាជីវៈច្បាស់លាស់ដែលផ្សាភ្ជាប់ទៅនឹងការដំឡើងដំណែង និងប្រាក់បៀវត្សរ៍ ព្រមទាំងកង្វះសម្ភារបរិក្ខារ និង មូលនិធិសម្រាប់សកម្មភាពស្រាវជ្រាវ" (ទំព័រ១២)។ ការស្រាវជ្រាវដោយវិទ្យាស្ថានខ្មែរសម្រាប់កិច្ចសហប្រតិបត្តិការនិងសន្តិភាព (Cambodian Institute for Cooperation and Peace [CICP], 2016) ក៏បានរកឃើញបញ្ហាប្រឈមមួយចំនួនចំពោះការអភិវឌ្ឍការស្រាវជ្រាវក្នុងប្រទេសកម្ពុជាផងដែរ។ បញ្ហាទាំងនោះ រួមមានចំនួនអ្នកស្រាវជ្រាវក្នុងស្រុកដែលមានសមត្ថភាពខ្ពស់នៅមានកម្រិត បរិក្ខារស្រាវជ្រាវមានកម្រិត និងសកម្មភាពស្រាវជ្រាវក្នុងស្រុកក៏នៅមានកម្រិត។

អ្នកស្រាវជ្រាវដទៃទៀតក៏បានពិភាក្សាអំពីបញ្ហាប្រឈមផ្សេងៗ ដែលជាឧបសគ្គចម្បងក្នុងការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា និងក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។ ជាឧទាហរណ៍ Keuk (2015) បានរកឃើញថាចំណេះដឹងអំពីការស្រាវជ្រាវ និងការគាំទ្រពីស្ថាប័នសម្រាប់ការស្រាវជ្រាវនៅមានកម្រិត ដែលជាឧបសគ្គចម្បងចំពោះការអភិវឌ្ឍការស្រាវជ្រាវផ្នែកបង្រៀនភាសាអង់គ្លេសក្នុងប្រទេសកម្ពុជា។ Kitamura et al. (2016) បានរកឃើញថាសកម្មភាពស្រាវជ្រាវរបស់គ្រូបង្រៀនសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា ជួបប្រទះបញ្ហាប្រឈមសំខាន់ៗជាច្រើន ដូចជាបន្ទុកនៃការបង្រៀនមានច្រើន កង្វះមូលនិធិស្រាវជ្រាវ និងកង្វះការគាំទ្រដល់ការស្រាវជ្រាវ។ Oleksiyenko & Ros (2019) ក៏បានរកឃើញថាសកម្មភាពស្រាវជ្រាវរបស់គ្រូបង្រៀនសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា ត្រូវបានរារាំងយ៉ាងខ្លាំងដោយកត្តាកង្វះការគាំទ្រពីស្ថាប័ន និងកង្វះការផ្តល់តម្លៃពីសង្គមចំពោះលទ្ធផលដែលចេញពីការស្រាវជ្រាវ។

ការសិក្សាថ្មីៗរបស់ Heng et al. (2022a, 2022b) ក៏បានលើកឡើងពីបញ្ហាប្រឈមនានាទាក់ទងនឹងការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ ដូចដែល Heng et al. (2022a) បានរកឃើញ គ្រូបង្រៀនសាកលវិទ្យាល័យកម្ពុជាមានការយល់ដឹងផ្សេងគ្នាទាក់ទងទៅនឹងការស្រាវជ្រាវ ដោយអ្នកខ្លះសន្មត់ថា "ការអានអ្វីមួយនៅលើបណ្តាញអ៊ីនធឺណិត ឬការអានសៀវភៅផ្សេងៗ ដើម្បីរៀបចំសម្រាប់ការបង្រៀន គឺជាការស្រាវជ្រាវ" (ទំព័រ៥)។ ការយល់ដឹងលើការស្រាវជ្រាវមិនច្បាស់លាស់នេះ មានឥទ្ធិពលអវិជ្ជមានលើសមត្ថភាពបង្កើតចំណេះដឹង និងការចូលរួមក្នុងសហគមន៍ស្រាវជ្រាវអន្តរជាតិរបស់អ្នកស្រាវជ្រាវកម្ពុជា។ ការស្រាវជ្រាវនោះក៏បានរកឃើញដែរថា គ្រូបង្រៀនសាកលវិទ្យាល័យកម្ពុជាភាគច្រើន "និយាយផ្សេងធ្វើផ្សេងទាក់ទងទៅនឹងការស្រាវជ្រាវ" (ទំព័រ៥)។ ឃ្លានេះមានន័យថា ពួកគេមិនបានចូលរួមយ៉ាងសកម្មក្នុងការស្រាវជ្រាវនោះទេ បើទោះបីជាពួកគេនិយាយថាការស្រាវជ្រាវមានសារៈសំខាន់ខ្លាំងក៏ដោយ។

លើសពីនេះ Heng et al. (2022a) ក៏បានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗដែលជាឧបសគ្គចំពោះការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ បញ្ហាប្រឈមសំខាន់ៗទាំងនោះ រួមមានកង្វះគ្រូបង្រៀនសាកលវិទ្យាល័យដែលមានសញ្ញាបត្របណ្ឌិត កង្វះការសហការពីភាគីពាក់ព័ន្ធ គោលនយោបាយផ្សេងៗនៅមិនទាន់ស៊ីសង្វាក់គ្នា សេរីភាពសិក្សាធិការនៅមានកម្រិត និងបញ្ហាអភិបាលកិច្ចនៅឧត្តមសិក្សា។ ដូចគ្នានេះដែរ Heng et al. (2022b) ក៏បានរកឃើញបញ្ហាប្រឈមជាច្រើន ដែលរារាំងអ្នកស្រាវជ្រាវកម្ពុជាពីការចូលរួមក្នុងការស្រាវជ្រាវឱ្យបានសកម្ម ដែលរួមមាន "កង្វះនៃកាតព្វកិច្ចស្រាវជ្រាវក្នុងស្ថាប័ន កង្វះការលើកទឹកចិត្ត និងមូលនិធិស្រាវជ្រាវ និងកង្វះគោលនយោបាយស្រាវជ្រាវច្បាស់លាស់ដែលចាត់ទុកការស្រាវជ្រាវជាផ្នែកសំខាន់មួយនៃទំនួលខុសត្រូវការងាររបស់អ្នកស្រាវជ្រាវ" (ទំព័រ១៣)។

ដូចគ្នានេះដែរ ការសិក្សាថ្មីមួយរបស់ Heng (2022b) បានបង្ហាញពីកត្តាដែលរារាំងការចូលរួមក្នុងការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវកម្ពុជា។ កត្តារារាំងទាំងនោះត្រូវបានបែងចែកជាបីកម្រិត៖ ថ្នាក់ជាតិ ស្ថាប័ន និងបុគ្គល។ នៅថ្នាក់ជាតិ បញ្ហា រួមមានសេរីភាពសិក្សាធិការនៅមានកម្រិត កង្វះមូលនិធិជាតិសម្រាប់ការស្រាវជ្រាវ កង្វះយន្តការលើកកម្ពស់អ្នកសិក្សាស្រាវជ្រាវ ប្រាក់ខែសម្រាប់គ្រូបង្រៀនសាកលវិទ្យាល័យនៅទាប និងបញ្ហាផ្សេងៗទៀត។ នៅកម្រិតស្ថាប័ន មានកត្តារារាំងដូចជាកង្វះការគាំទ្រ និងការលើកទឹកចិត្តសម្រាប់ការស្រាវជ្រាវ កង្វះកាតព្វកិច្ចស្រាវជ្រាវក្នុងស្ថាប័ន កង្វះគោលនយោបាយស្រាវជ្រាវច្បាស់លាស់ និងកង្វះទិសដៅស្រាវជ្រាវរបស់ស្ថាប័ន។ នៅកម្រិតបុគ្គល Heng (2022b) បានរៀបរាប់ពីឧបសគ្គចំនួន៧ ដែលទាក់ទងនឹងបញ្ហាពេលវេលា គំនិតយល់ថាការស្រាវជ្រាវមិនផ្តល់អត្ថប្រយោជន៍ច្រើន កង្វះចំណេះដឹងផ្នែកស្រាវជ្រាវ កង្វះចំណេះដឹងផ្នែកភាសាអង់គ្លេស កង្វះបុគ្គលគំរូផ្នែកស្រាវជ្រាវ កង្វះចំណាប់អារម្មណ៍និងការលើកទឹកចិត្តចំពោះការស្រាវជ្រាវ និងកង្វះការប្តេជ្ញាចិត្តលើការស្រាវជ្រាវ។

សរុបមក យើងសង្កេតឃើញថា បញ្ហាប្រឈមជាច្រើនបន្តរាំងដល់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ ដូច្នេះ ការផ្តល់អនុសាសន៍គោលនយោបាយមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ ដើម្បីធានាថាការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជាអាចដំណើរការទៅមុខបានល្អ។

## អនុសាសន៍គោលនយោបាយ

### បង្កើតចក្ខុវិស័យ និងគោលនយោបាយស្រាវជ្រាវច្បាស់លាស់

ដើម្បីលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា ចាំបាច់ត្រូវមានចក្ខុវិស័យ និងគោលនយោបាយស្រាវជ្រាវច្បាស់លាស់ ទាំងថ្នាក់ជាតិ និងស្ថាប័ន។ នៅក្នុងយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សាឆ្នាំ២០២១-២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បានគូសបញ្ជាក់អំពីគោលបំណងបង្កើនសកម្មភាពស្រាវជ្រាវប្រតិបត្តិ ដែលឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិឱ្យបានចំនួន៥ដង (MoEYS, 2021)។ យុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រួមមានការគាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុវត្តគោលនយោបាយស្រាវជ្រាវក្នុងស្ថាប័ន ការផ្តល់មូលនិធិវិនិយោគលើការស្រាវជ្រាវ និងការរៀបចំកិច្ចពិភាក្សា ឬវេទិកាស្រាវជ្រាវ ដើម្បីឱ្យអ្នកស្រាវជ្រាវបង្ហាញពីលទ្ធផល ឬផលិតផលស្រាវជ្រាវ។ ដូច្នេះ ទោះបីបច្ចុប្បន្នមានគោលនយោបាយជំរុញការស្រាវជ្រាវក៏ដោយ ក្រសួងអប់រំក៏ត្រូវកំណត់ឱ្យច្បាស់អំពីវិធីសាស្ត្រលើកទឹកចិត្តអ្នកស្រាវជ្រាវ និងវិធីសាស្ត្រលើកកម្ពស់ការស្រាវជ្រាវប្រតិបត្តិ ឬសកម្មភាពស្រាវជ្រាវផ្សេងទៀតនៅឧត្តមសិក្សាកម្ពុជា។

លើសពីនេះ វាជាការសំខាន់ណាស់ដែលក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្ត ឬតម្រូវឱ្យគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ជាពិសេសគ្រឹះស្ថានដែលមានបំណងចង់ក្លាយជាសាកលវិទ្យាល័យដែលផ្តោតលើការស្រាវជ្រាវ បង្កើតចក្ខុវិស័យ និង

គោលនយោបាយស្រាវជ្រាវច្បាស់លាស់ ព្រមទាំងមានការប្ដេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវលើវិស័យអាទិភាពច្បាស់លាស់។ សាកលវិទ្យាល័យឈានមុខគេមួយចំនួន ដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតគោលនយោបាយស្រាវជ្រាវផ្ទាល់ខ្លួន។ ប៉ុន្តែនេះមិនមែនមានន័យថា គ្រប់សាកលវិទ្យាល័យកម្ពុជាទាំងអស់មានគោលនយោបាយស្រាវជ្រាវច្បាស់លាស់នោះទេ។ ប្រសិនបើសាកលវិទ្យាល័យគ្មានគោលនយោបាយស្រាវជ្រាវច្បាស់លាស់ ដែលចែងពីការប្ដេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុ កាតព្វកិច្ច ឬការលើកទឹកចិត្តចំពោះការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ វានឹងមានភាពលំបាកសម្រាប់សាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា ធ្វើការលើកកម្ពស់ការស្រាវជ្រាវ។ នៅពេលដែលសាកលវិទ្យាល័យនីមួយៗមានចក្ខុវិស័យ ឬគោលនយោបាយស្រាវជ្រាវច្បាស់លាស់ សាកលវិទ្យាល័យក៏ត្រូវត្រួតពិនិត្យការអនុវត្តគោលនយោបាយនោះផងដែរ ពីព្រោះជារឿយៗគោលនយោបាយមួយត្រូវបានបង្កើតមកយ៉ាងល្អ ប៉ុន្តែការអនុវត្តគឺជាបញ្ហា ដែលនាំឱ្យការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជានៅតែមានការអភិវឌ្ឍតិចតួច (សូមអាន Sok & Bunry, 2021)។

## បង្កើតយន្តការគាំទ្រការស្រាវជ្រាវ

ដូចដែលបានពិភាក្សាខាងលើ វត្តមាននៃចក្ខុវិស័យ និងគោលនយោបាយស្រាវជ្រាវច្បាស់លាស់ គឺចាំបាច់ណាស់ ប៉ុន្តែយន្តការសម្រាប់គាំទ្រការស្រាវជ្រាវក៏មានសារៈសំខាន់ដូចគ្នា។ យន្តការគាំទ្រការស្រាវជ្រាវ គឺជាកត្តាជំនួយដល់ការអនុវត្តគោលនយោបាយស្រាវជ្រាវថ្នាក់ជាតិ ឬស្ថាប័ន។ ជាទូទៅ គោលនយោបាយស្រាវជ្រាវមានលក្ខណៈទូលំទូលាយ ដូច្នេះយើងត្រូវមានយន្តការគាំទ្រការស្រាវជ្រាវជាក់លាក់ ដើម្បីជំរុញចំណាប់អារម្មណ៍ចំពោះការស្រាវជ្រាវ ក្នុងចំណោមអ្នកស្រាវជ្រាវ អ្នកសិក្សា និងនិស្សិត។ យន្តការគាំទ្រការស្រាវជ្រាវអាចរួមបញ្ចូលនូវយុទ្ធសាស្ត្រ ឬគំនិតផ្ដួចផ្ដើមផ្សេងៗ ដែលរៀបចំឡើង ដើម្បីលើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវ ដែលរួមមានការផ្តល់មូលនិធិស្រាវជ្រាវមានលក្ខណៈប្រកួតប្រជែងទាំងក្នុងកម្រិតជាតិ និងស្ថាប័ន ការផ្តល់ពានរង្វាន់ស្រាវជ្រាវ ការលើកទឹកចិត្តចំពោះការស្រាវជ្រាវដែលមានគុណភាព កម្មវិធីបណ្តុះបណ្តាល ឬមគ្គុទេសក៍ស្រាវជ្រាវ កម្មវិធីអាហារូបករណ៍សម្រាប់អ្នកស្រាវជ្រាវ កម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវ និងវេទិកាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញឱ្យសាកលវិទ្យាល័យសហការជាមួយវិស័យឯកជន ឬឧស្សាហកម្ម។ល។

រហូតមកដល់ពេលនេះ ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាមួយចំនួនបាននិងកំពុងអនុវត្តកម្មវិធី និងគំនិតផ្តួចផ្តើមរបស់ខ្លួន ដើម្បីលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សា។ ជាឧទាហរណ៍ ក្រសួងបានដាក់ចេញនូវគោលនយោបាយ និងអនុវត្តគម្រោងលើកកម្ពស់ការស្រាវជ្រាវមួយចំនួន រួមទាំងកម្មវិធីមគ្គុទេសក៍ស្រាវជ្រាវ ខណៈពេលដែលគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាមួយចំនួន ដូចជាវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក៏បានខិតខំប្រឹងប្រែងលើកកម្ពស់សកម្មភាពស្រាវជ្រាវ និងការបោះពុម្ពផ្សាយក្នុងចំណោមអ្នកស្រាវជ្រាវ និងគ្រូបង្រៀនរបស់ខ្លួនផងដែរ (សូមអាន Heng & Sol, 2021; Sok & Bunry, 2021)។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវមានកម្មវិធី ឬគំនិតផ្តួចផ្តើមដែលជំរុញការស្រាវជ្រាវបន្ថែមទៀត ជាពិសេសកម្មវិធីដែលមានបំណងអភិវឌ្ឍអ្នកស្រាវជ្រាវថ្មី ឬគាំទ្រអ្នកស្រាវជ្រាវវ័យក្មេង ដើម្បីកសាងសន្ទុះវិជ្ជមានសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវដែលមានដំណើរការល្អនៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។

## បង្កើតបរិយាកាសអំណោយផលដល់ការស្រាវជ្រាវ

ការមានគោលនយោបាយស្រាវជ្រាវច្បាស់លាស់ និងយន្តការគាំទ្រការស្រាវជ្រាវដែលដំណើរការល្អ ក៏ប្រហែលជាមិនទាន់គ្រប់គ្រាន់ ដើម្បីអភិវឌ្ឍវប្បធម៌ស្រាវជ្រាវប្រកបដោយនិរន្តរភាពនោះទេ ព្រោះនៅមានកិច្ចការជាច្រើនទៀត ដែលយើងត្រូវធ្វើ។ ជាក់ស្តែង វាមានសារៈសំខាន់ណាស់ក្នុងការបណ្តុះបរិយាកាសដែលអំណោយផលដល់ការស្រាវជ្រាវ នៅក្នុងកម្រិតជាតិ និងស្ថាប័ន។ ក្នុងន័យនេះ គួរមានការយកចិត្តទុកដាក់ខ្ពស់ទាំងក្នុងកម្រិតជាតិ និងស្ថាប័ន។ នៅកម្រិតជាតិ គួរមានការលើកកម្ពស់សេរីភាពសិក្សាធិការ ដែលជាកត្តាសំខាន់មួយក្នុងការជំរុញការស្រាវជ្រាវ ដោយសារការស្រាវជ្រាវផ្សេងៗបានបង្ហាញថា សេរីភាពសិក្សាធិការដែលនៅមានកម្រិត គឺជាឧបសគ្គចម្បងមួយក្នុងចំណោមឧបសគ្គផ្សេងទៀត ដែលរារាំងការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា និងក្នុងប្រទេសកម្ពុជាទាំងមូល (សូមអាន Chet, 2009; CICP, 2016; Heng, 2022b)។ នៅកម្រិតស្ថាប័ន ការស្រាវជ្រាវត្រូវតែជាផ្នែកមួយនៃបេសកកម្មស្នូលរបស់សាកលវិទ្យាល័យ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយចាំបាច់ត្រូវក្លាយជាមូលដ្ឋានសម្រាប់ការដំឡើងប្រាក់បៀវត្សរ៍ ឬមុខតំណែង ការផ្តល់លាភការ ក៏ដូចជាការជ្រើសរើស និងការរក្សាទុកអ្នកសិក្សាស្រាវជ្រាវ។

ដើម្បីបង្កើតបរិយាកាសដែលអំណោយផលដល់ការស្រាវជ្រាវ យើងក៏ត្រូវបង្កើតឱកាសផ្សេងៗដែលគាំទ្រសកម្មភាពស្រាវជ្រាវ។ ឱកាសទាំងនោះអាចជាបទបង្ហាញ ឬកិច្ចពិភាក្សាស្រាវជ្រាវសាធារណៈ វគ្គបណ្តុះបណ្តាលស្រាវជ្រាវ សិក្ខាសាលាស្រាវជ្រាវ កិច្ចសហការស្រាវជ្រាវ បណ្តាញអ្នកស្រាវជ្រាវ និងសហគមន៍ស្រាវជ្រាវ។ល។ នៅពេលដែលសកម្មភាពស្រាវជ្រាវមានវត្តមានកាន់តែច្រើននៅតាមគ្រឹះស្ថានឧត្តមសិក្សា និងក្នុងសង្គម មនុស្សកាន់តែច្រើននឹងដឹងលឺពីការស្រាវជ្រាវ ដែលប្រការនេះនឹងផ្តល់ឱកាសកាន់តែច្រើនឱ្យពួកគេឈ្វេងយល់អំពីសកម្មភាពស្រាវជ្រាវផ្សេងៗ ដែលកើតឡើងនៅជុំវិញខ្លួនគេ។ បរិយាកាសនេះនឹងជួយជំរុញការអភិវឌ្ឍវប្បធម៌សង្គមមួយ ដែលមានការយល់ដឹងថាការស្រាវជ្រាវមិនមែនតែជាការងាររបស់អ្នកស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវនោះទេ ប៉ុន្តែមនុស្សផ្សេងទៀត រួមទាំងគ្រូបង្រៀន និស្សិត និងយុវជន ក៏អាចធ្វើការស្រាវជ្រាវបានដែរ។

## សេចក្តីសន្និដ្ឋាន

អត្ថបទសង្ខេបគោលនយោបាយនេះ បានពិភាក្សាអំពីកាលានុវត្តភាព និងបញ្ហាប្រឈមក្នុងការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ កាលានុវត្តភាពសំខាន់ៗដែលបានពិភាក្សា រួមមានការបង្កើតគោលនយោបាយស្រាវជ្រាវ និងការផ្សព្វផ្សាយសៀវភៅណែនាំដែលផ្តោតលើការស្រាវជ្រាវ សេចក្តីប្រកាសស្តីពីការជ្រើសរើសនិងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ការបង្កើតវេទិកាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវថ្មីៗ ដូចជាសន្និសីទ និងទស្សនាវដ្តីស្រាវជ្រាវ ព្រមទាំងការអនុវត្តគម្រោងស្រាវជ្រាវ និងកម្មវិធីគាំទ្រការស្រាវជ្រាវផ្សេងៗ។ ចំពោះបញ្ហាប្រឈមវិញ មានច្រើនសណ្ឋាន រួមមានប្រាក់បៀវត្សរ៍ទាប កង្វះអ្នកស្រាវជ្រាវក្នុងស្រុកដែលមានសមត្ថភាពខ្ពស់ កង្វះចំណេះដឹង និងជំនាញស្រាវជ្រាវ កង្វះមូលនិធិ និងការលើកទឹកចិត្តចំពោះការស្រាវជ្រាវ កង្វះការគាំទ្រពីស្ថាប័ន កង្វះសេរីភាពសិក្សាធិការ កង្វះកាតព្វកិច្ចស្រាវជ្រាវក្នុងស្ថាប័ន និងកង្វះការប្តេជ្ញាចិត្ត និងហិរញ្ញវត្ថុចំពោះការស្រាវជ្រាវ។ល។ អត្ថបទសង្ខេបគោលនយោបាយនេះ ក៏បានលើកឡើងនូវអនុសាសន៍មួយចំនួន ដែលភាគីពាក់ព័ន្ធគួរយកទៅពិចារណា ដើម្បីជំរុញការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជាបន្ថែមទៀត។ ជាក់ស្តែង អនុសាសន៍សម្រាប់គោលនយោបាយខាងលើ ផ្តោតលើចំនុចសំខាន់ៗចំនួន៣ចំនុច ដែលទាក់ទងនឹងតួនាទីនៃចក្ខុវិស័យ និងគោលនយោបាយស្រាវជ្រាវ យន្តការគាំទ្រការស្រាវជ្រាវ និងបរិយាកាសស្រាវជ្រាវ។

សរុបជារួម ដើម្បីបន្តកសាងសន្ទុះវិជ្ជមានសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវក្នុងអនុវិស័យឧត្តមសិក្សាកម្ពុជា ដែលមានការរីកចម្រើនខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ វាជាការសំខាន់ណាស់ដែលយើងត្រូវពិចារណាលើកត្តាផ្សេងៗ ដែលអាចជួយសម្រួលដល់សកម្មភាពស្រាវជ្រាវ ជំរុញចំណាប់អារម្មណ៍លើការស្រាវជ្រាវ និងលើកទឹកចិត្តអ្នកសិក្សាស្រាវជ្រាវម្នាក់ៗ ឱ្យបង្កើនការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការចូលរួមក្នុងការស្រាវជ្រាវ។ ការអភិវឌ្ឍការស្រាវជ្រាវ និងការបណ្តុះវប្បធម៌ស្រាវជ្រាវដ៏ល្អមួយ ទាំងថ្នាក់ជាតិ ឬស្ថាប័ន ទាមទារមិនត្រឹមតែពេលវេលាច្រើន ការខិតខំប្រឹងប្រែងខ្លាំងក្លា និងការប្តេជ្ញាចិត្តខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏ទាមទារឱ្យមានការវិនិយោគលើការស្រាវជ្រាវច្បាស់លាស់ និងមាននិរន្តរភាពទាំងនៅថ្នាក់ជាតិ និងកម្រិតស្ថាប័ន។ ការវិនិយោគច្បាស់លាស់នឹងធានាបាននូវនិរន្តរភាពនៃសកម្មភាពស្រាវជ្រាវ និងការអនុវត្តយន្តការគាំទ្រការស្រាវជ្រាវរយៈពេលវែង ជាពិសេសបង្កើតឱ្យមានប្រព័ន្ធលើកទឹកចិត្តអ្នកស្រាវជ្រាវច្បាស់លាស់ ដែលអាចជួយកសាងវប្បធម៌ស្រាវជ្រាវដ៏រឹងមាំមួយនៅពេលអនាគត។

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់អ្នកត្រួតពិនិត្យជំនាញរបស់ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម សម្រាប់មតិយោបល់កែលម្អលើអត្ថបទសង្ខេបគោលនយោបាយនេះ។ ខ្លឹមសារក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីទស្សនៈ ឬនិន្នាការនយោបាយរបស់ក្រុមណាមួយឡើយ។

## ឯកសារយោង ( References )

Chet, C. ( 2009 ). Higher education in Cambodia. In Y. Hirosato & Y. Kitamura ( Eds. ), *The political economy of educational reforms and capacity development in Southeast Asia: Cases of Cambodia, Laos and Vietnam* ( Vol. 13, pp. 153-165 ). Springer.

CICP. ( 2016 ). *Doing research in Cambodia: Making models that build capacity*. Cambodian Institute for Cooperation and Peace.

DSR. ( 2022a ). *សៀវភៅព័ត៌មាន វេទិកាស្រាវជ្រាវថ្នាក់ជាតិ លើកទី៤ «ការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា»* [Information book on the 4th National Research Forum on "Promoting research and innovation for Cambodia's socioeconomic development"]. Department of Scientific Research, Ministry of Education, Youth and Sport.

DSR. ( 2022b ). *សៀវភៅណែនាំស្តីពី ការបង្កើត គ្រប់គ្រង និងអភិវឌ្ឍទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ* [Manual on the establishment, management, and development of scientific journals]. Department of Scientific Research, Ministry of Education, Youth and Sport.

DSR. ( 2022c ). *សៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា* [Manual on research management at higher education institutions]. Department of Scientific Research, Ministry of Education, Youth and Sport.

Heng, K. ( 2020 ). *New hope for a research culture in Cambodia*. Cambodia Development Center. https://cd-center.org/2020/10/23/new-hope-for-a-research-culture-in-cambodia/

Heng, K. (2022a). *Cambodian youth and the knowledge sector: Challenges, opportunities, and recommendations*. The Asia Foundation.

Heng, K. (2022b). *Research engagement of Cambodian academics: Challenges and opportunities* [Doctoral dissertation, The University of Queensland]. https://espace.library.uq.edu.au/view/UQ:56214e1

Heng, K., Hamid, M. O., & Khan, A. (2022a). Academics' conceptions of research and the research-teaching nexus: Insights from Cambodia. *International Journal of Educational Development*, *90*, 1-11.

Heng, K., Hamid, M. O., & Khan, A. (2022b). Research engagement of academics in the Global South: The case of Cambodian academics. *Globalisation, Societies and Education*, 1-16.

Heng, K., & Sol, K. (2021). Academic research in Cambodia: Progress, challenges, and ways forward. *Cambodian Journal of Educational Research*, *1*(2), 6-23.

Heng, K., & Sol, K. (2022). *Education: Key to making Cambodia great again*. Cambodia Development Center. https://www.cd-center.org/education-key-to-making-cambodia-great-again/

Heng, K., Sol, K., & Em, S. (2023). COVID-19 and digital transformation of Cambodian higher education: Opportunities, challenges, and the way forward. In P. O. de Pablos, X. Zhang, and M. N. Almunawar (Eds.), *Handbook of research on education institutions, skills, and jobs in the digital era* (pp. 307-327). IGI Global. https://doi.org/10.4018/978-1-6684-5914-0.ch018

Keuk, C. N. (2015). *Investigating communities of practice and ELT teacher research in Cambodia* [Doctoral dissertation, Macquarie University]. https://www.researchonline.mq.edu.au/vital/access/manager/Repository/mq:44046

Kitamura, Y., Umemiya, N., Hirosato, Y., & Dy, S. S. (2016). Quality of education and research in Cambodian higher education institutions. In Y. Kitamura, D. Edwards Jr, S. Chhinh, & H. Williams (Eds.), *The political economy of schooling in Cambodia: Issues of quality and equity* (pp. 205-218). Springer.

Kwok, K.-W., Chan, S., Heng, C., Kim, S., Neth, B., & Thon, V. (2010). *Scoping study: Research capacities of Cambodia's universities*. The Development Research Forum in Cambodia.

Mak, N. (2022, October 20, 2022). *Directions for research in higher education.* Paper presented at the 4th National Research Forum, Phnom Penh, Cambodia.

MoEYS. (2019). *Education strategic plan 2019-2023*. Ministry of Education, Youth and Sport.

MoEYS. (2021). *យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា ២០២១-២០៣០* [Higher education strategy 2021-2030]. Ministry of Education, Youth and Sport.

Oleksiyenko, A., & Ros, V. (2019). Cambodian lecturers′ pursuit of academic excellence: Expectations vs. reality. *Asia Pacific Journal of Education*, *39*(2), 222-236.

Royal Government of Cambodia. (2018). *Rectangular strategy for growth, employment, equity, and efficiency (Phase 4) of the Royal Government of Cambodia*. Royal Government of Cambodia.

Sok, S., & Bunry, R. (2021). Internationalization of higher education in Cambodia: toward an agenda for higher education development. *International Journal of Comparative Education and Development*, *23*(3), 193-211.